រដ្ឋសភាជាតិក្នុងខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០១១ គឺជារយៈពេលវិស្សមកាលនៃចន្លោះសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៦ និងលើកទី៧ដែលស្ថិតនៅក្នុងរយៈពេលនេះ តំណាងរាស្ត្រមានឱកាសច្រើនជួបជាមួយនឹងប្រជាពលរដ្ឋជាម្ចាស់ឆ្នោត ដើម្បីនឹងជួយដោះស្រាយនូវបញ្ហាផ្សេងៗ ក៏ដូចជាពង្រឹងសកម្មជនបក្ស ស្របពេលដែលកម្ពុជាកំពុងរៀបចំឲ្យមានពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ខាងមុខ។

## ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖

- គណបក្ស ប្រជាជនកម្ពុជា
- គណបក្ស សមរង្ស៊ី
- គណបក្ស សិទ្ធិមនុស្ស
- គណបក្ស ហ្វ៊ុនស៊ិនប៉ិច
- គណបក្ស នរោត្តម រណឫទ្ធិ

តាមទិន្នន័យខុមហ្វ្រែលដែលទទួលបានបង្ហាញថា ក្នុងរយៈពេល៣ខែនេះ (កក្កដា ដល់កញ្ញា ២០១១) អ្នកតំណាងរាស្ត្របានចុះមូលដ្ឋានថយចុះជាងត្រីមាសមុន (មេសា-មិថុនា ២០១១ ជាពេលបើកសម័យប្រជុំរបស់រដ្ឋសភាក្នុងការពិភាក្សា និងអនុម័តច្បាប់ផ្សេងៗ)។

ក្នុងរយៈពេលនេះ មានអ្នកតំណាងរាស្ត្រយ៉ាងតិច៨១រូប (ឬ៦៦% នៃអ្នកតំណាងរាស្ត្រសរុប១២៣រូប) បានចុះមូលដ្ឋានសរុបបានយ៉ាងតិច ៥១៩លើក គឺតិចជាងរយៈពេល៣ខែមុន ប្រមាណ៧% (ពីខែមេសា ដល់មិថុនា ២០១១ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានសរុប ៥៥៨លើក)។

ទោះបីយ៉ាងណា ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងមណ្ឌលចំនួន២ គឺមណ្ឌលកែប និងមណ្ឌលគីរីនោះទេ។ ដោយឡែក ខេត្តកែបមិនទាន់មានការិយាល័យតំណាងរាស្ត្រនៅឡើយទេ។

***<u>តារាងទី ១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស</u>***

| គោលបំណងនៃការចុះមូលដ្ឋានទាំង ៥១៩លើក របស់តំណាងរាស្ត្រទាំង ៨១រូប | គណបក្សនយោបាយ | | | | | សរុបគោលបំណង |
|---|---|---|---|---|---|---|
| | ៥៥រូប | ១៩ រូប | ៣ រូប | ២ រូប | ២ រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ១១៩ (៥០%) | ៣៥ (៣០%) | ៨១ (៥៧%) | ២ (១០%) | ០ | ២៣៧ (៤៦%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស | ៦៤ (២៧%) | ៧១ (៦១%) | ៦០ (៤២%) | ១៤ (៧០%) | ១ (៥០%) | ២១០ (៤០%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៤៧ (២០%) | ០ | ០ | ៤ (២០%) | ០ | ៥១ (១០%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៤ (២%) | ៤ (៣%) | ២ (១%) | ០ | ១ (៥០%) | ១១ (២%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ៣ (១%) | ៧ (៦%) | ០ | ០ | ០ | ១០ (២%) |

| | | | | | | |
|---|---|---|---|---|---|---|
| **សរុបគោលបំណងតាមគណបក្ស** | **២៣៧** | **១១៧** | **១៤៣** | **២០** | **២** | **៥១៩** (១00%) |

តារាងទី១បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់ ២៣៧លើក (ឬ ៤៦% នៃការចុះមូលដ្ឋានសរុប)។ ការចុះអមដំណើរថ្នាក់ដឹកនាំ១០%។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន៤០% ដែលមានការកើនឡើងជាងរយៈពេល៣ខែមុនៗទៀត ព្រោះជាកំឡុងពេលចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះសំរាប់ការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ ខាងមុខនេះដែលគណបក្សនីមួយៗចុះដើម្បីពង្រឹងបក្ស និងសកម្មជនរបស់គាត់ឲ្យទៅចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះ។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈភាគច្រើនស្តីពីវេទិកាតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដែលរៀបចំដោយវិទ្យាស្ថានជាតិលទ្ធិប្រជាធិបតេយ្យ (អិន ឌី អាយ) និងវេទិកាសិទ្ធិមនុស្សរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានចំនួនតិចតួចប៉ុណ្ណោះសរុបបាន ១១លើក (២%នៃការចុះមូលដ្ឋានសរុប)។ ចំណែកការចុះអន្តរាគមន៍វិញ ភាគច្រើនផ្តោតលើការអន្តរាគមន៍លើបញ្ហាដីធ្លីរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ វិវាទដីធ្លីរវាងប្រជាជននិងអាជ្ញាធរ ក្រុមហ៊ុនឯកជននានា បញ្ហាទឹកជំនន់នៅតែមានតិចតួចនៅឡើយ បើទោះជាកើនជាង ៣ខែមុនដែលមានតែ ៨ដង គឺត្រឹម ១០លើក ស្មើនឹង២%នៃការចុះមូលដ្ឋានសរុប។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៥៥រូប ចុះបានសរុប ២៣៧លើក)**៖ ជាចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានច្រើនជាងគណបក្សផ្សេងៗ។ ក្នុងនោះ ៥០%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺក្នុងគោលបំណងសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា (១១៩លើក) និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន (២០%)។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក៏ចុះមូលដ្ឋាន ក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួន ដែលសរុបមាន២៧%។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈរួមគ្នាមាន២% (៤លើក) និងការអន្តរាគមន៍មានចំនួន១% (៣លើក)។

អ្នកតំណាងរាស្ត្រស្ត្រីភាគច្រើន ក្នុងចំណោមគណបក្សនេះបានចុះមូលដ្ឋានបានច្រើននាំមុខគេក្នុងករណីមួយៗ ដូចជាអ្នកតំណាងរាស្ត្រ **កែ ច័ន្ទមុនី** អ្នកតំណាងរាស្ត្រ **ឡោក ខេង** អ្នកតំណាងរាស្ត្រ **ត្រឹង ថាវី** និងអ្នកតំណាងរាស្ត្រ **ម៉ែន សំអន**។ ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖

អ្នកតំណាងរាស្ត្រ **កែ ច័ន្ទមុនី** ចុះមកចូលរួមសម្របសម្រួលក្នុងការដោះស្រាយបញ្ហាដីធ្លីរបស់ប្រជាជនដែលមានទំនាស់ដីធ្លីរវាងវត្តថ្មល់តាសែង និងប្រជាពលរដ្ឋដែលនៅជាប់របងវត្តថ្មល់តាសែង នៅមន្ទីរធម្មការ និងសាសនាខេត្តនៅឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១។ ការសម្របម្រួលនេះ អ្នកតំណាងរាស្ត្របានចំណាយរយៈពេលអស់២ថ្ងៃ ក្នុងការធ្វើយ៉ាងណាដើម្បីឲ្យភាគីសងខាងព្រមទទួលយកនូវការដំណោះស្រាយមួយសមហេតុសមផល។ ទោះបីជាឥឡូវនេះ មិនទាន់មានលទ្ធផលពីការអន្តរាគមន៍ដោយសារភាគីនៅមិនទាន់បានស្រុះស្រួលនៅឡើយ តែអ្នកតំណាងរាស្ត្រ **កែ ច័ន្ទមុនី** បានទុករយៈពេលបន្តិចសំរាប់ភាគីទាំងពីរដើម្បីពិចារណា។ អ្នកតំណាងរាស្ត្ររូបនេះបានមានប្រសាសន៍ថា គាត់បានខិតខំដើម្បីជួយរាស្ត្រពេលមានបញ្ហា បើទោះជាពេលខ្លះមិនអាចដោះស្រាយបានជោគជ័យក៏ដោយ "*ទោះបីយ៉ាងណាសិទ្ធិសម្រេចមិនស្ថិតនៅលើខ្ញុំទេ តែយើងបានជួយដោះស្រាយនូវកង្វល់ចំពោះរាស្ត្រមាន*"។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី (១៩រូប ចុះសរុបបាន ១១៧លើក)៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានសួរសុខទុក្ខ(៣០% ឬ ៣៥លើក នៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) ប៉ុន្តែផ្តោតខ្លាំងលើការពង្រឹងបណ្តាញគណបក្ស (ស្មើនឹង៦១% ឬ៧១លើក)។ ចំណែកការចូលរួមវេទិកាសាធារណៈ និងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍មានចំនួនសរុបរៀងគ្នា ៣%(៤លើក) និង៧លើក (៦%)។ ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ ខាងគណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋាននេះទេ។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មានដូចជា៖

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញបានចុះជួយអន្តរាគមន៍ដីធ្លីរបស់ប្រជាពលរដ្ឋចំនួន៧ភូមិ នៅក្នុងឃុំព្រះនេត្រព្រះ ដែលកងពលរថក្រោះមាតុភូមិនិវត្តន៍បានយកអស់ជាង២០០ហិចតា ហើយបានទទួលយកពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន២២២គ្រួសារផ្សេងទៀត ទាក់ទងដីស្រែចំនួន៤៤៤ហិចតាដែលកន្លងមកត្រូវបានអ្នកមានអំណាចគ្រប់លំដាប់ថ្នាក់បានរំលោភយកគ្មានសល់ នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១១។

អ្នកតំណាងរាស្ត្ររូបនេះថានឹងយកសំណើនេះទៅសុំការអន្តរាគមន៍នៅសភា។ បញ្ហានេះមិនទាន់បានត្រូវដោះស្រាយនៅឡើយទេ។ តែទោះបីយ៉ាងណានៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១១ សង្កេតឃើញថា មានមន្ត្រីឃុំ និងគណៈអភិបាលស្រុកបានចុះទៅពិនិត្យ ហើយសន្យានឹងជួយដោះស្រាយនៅសាលាខេត្តបន្ទាប់។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស (៣រូប ចុះបានសរុប ១៤៣លើក)៖** តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើចុះសួរសុខទុក្ខ ចែកអំណោយដែលមានដល់ទៅ៥៧% (៨១លើក)នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន ៤២% (៦០លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ១% (២លើក)។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស សិទ្ធិមនុស្សមានដូចជា៖

អ្នកតំណាងរាស្ត្រ **គឹម សុខា** មណ្ឌលកំពង់ចាមបានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខជាមួយប្រជាពលរដ្ឋ នៅឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១១ ។ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាល **អ៊ូ ច័ន្ទឫទ្ធិ** បានអញ្ជើញចុះពង្រឹងសមត្ថភាពសកម្មជន និងថ្នាក់ដឹកនាំមូលដ្ឋាននៅស្រុកអង្គស្នួល ខេត្តកណ្តាល។ អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មណ្ឌលព្រៃវែង បានអញ្ជើញចូលរួមវេទិកាសាធារណៈដែលរៀបចំដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ( អ៊ិន ឌី អាយ) ស្តីពីតំណាងរាស្ត្រជួបម្ចាស់ឆ្នោត កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១១។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច (២រូប ចុះបានសរុប ២០លើក)៖** អ្នកតំណាងរាស្ត្រគណបក្សនេះទាំងពីររូបសុទ្ធតែបានចុះមូលដ្ឋានសរុប២០លើក ដោយផ្តោតលើការចុះសួរសុខទុក្ខ និងចែកអំណោយមាន ២លើក (១០%) ការពង្រឹងបក្សមាន១៤លើក ស្មើនឹង៧០% ហើយការចុះអមដំណើរថ្នាក់ដឹកនាំមាន៤លើក (ស្មើនឹង២០%នៃការចុះមូលដ្ឋានសរុប)។ អ្នកតំណាងរាស្ត្រ **ញឹក ប៊ុនឆៃ** មណ្ឌលបន្ទាយមានជ័យ កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ បានញើញចុះសំណេះសំណាលជាមួយថ្នាក់ដឹកនាំបក្សឃុំទាំង៧ ដែលមានអ្នកចូលរួមមាន៤៤នាក់ និងបានឧបត្ថម្ភថវិកាក្នុងម្នាក់ៗទទួលបាន ២០.០០០រៀល សារុង ១ ថ្នាំប៉ារ៉ាសេតាម៉ុល ១កំប៉ុង ថ្នាំវីតាមីន៣បន្ទះ សាប៊ូកូនក្មេង៣ដុំបសរុបថវិកា

១.១៣០.០០០រៀល នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ចំណែកអ្នកតំណាងរាស្ត្រ **គុជ ម៉ូលី** មណ្ឌលកំពង់ធំ បានអញ្ជើញ សំណេះសំណាល និងសួរសុខទុក្ខជាមួយអាជ្ញាធរ មន្ត្រីរាជការ និងប្រជាពលរដ្ឋខេត្តកោះកុង កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១១។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គណបក្សហ៊្វុនស៊ិនប៉ិចក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ នោះទេ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តម រណប្ញទ្ធិ (២រូប ចុះបាន ២លើក)៖** ខុមហ្វ្រែលទទួលបានព័ត៌មានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុប២លើក ក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាជន(១លើក) ចូលរួមវេទិកា(១លើក)។ អ្នកតំណាងរាស្ត្រ **យូ ហុកគ្រី** បានអញ្ជើញចូលរួមក្រោមវេទិកាក្រោមអធិបតីភាពសម្តេចក្រុមព្រះនរោត្តមរណប្ញទ្ធិ សំណេះសំណាលជាមួយក្រុមយុវជនគណបក្សជំរុញអោយទៅចុះឈ្មោះបោះឆ្នោតដែលនៅខណ្ឌចំការមន រាជធានីភ្នំពេញ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១។ តំណាងរាស្ត្រ **សៅ រានី** មណ្ឌលព្រៃវែង បានចូលរួមវេទិកាសាធារណៈស្តីពីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍រៀបចំដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ នៅឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

***ក្រាហ្វិទី២៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សចន្លោះពីខែកក្កដា-កញ្ញា ២០១១ ធៀបនឹងខែមេសា-មិថុនា ២០១១***




ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសិទ្ធិមនុស្សមានការកើនឡើងច្រើនជាងគេក្នុងត្រីមាសនេះ គឺដល់ទៅ២៥% ដែលមានចំនួន២០លើក (ក្នុងត្រីមាសមុនគឺមានត្រឹមតែ១៥លើក)។

បើគិតជាចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានច្រើនជាងគេ ដែលច្រើនតាមលំដាប់ ៤៦% និង២៨% នៃការចុះមូលដ្ឋានសរុប។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូប ក៏បានបង្កើនការចុះមូលដ្ឋានរបស់ខ្លួនរហូតដល់១៤៣លើក គឺកើនឡើងប្រមាណ២០% ធៀបនឹង៣ខែមុន (ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សបានចុះមូលដ្ឋានចំនួន ១០៩ លើក)។

ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជារវាង៣នេះ (កក្កដា-កញ្ញា) និង៣ខែមុនមិនមានការថយចុះទេគឺនៅដដែល ២៣៧លើក។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានថយចុះដល់៣៩% ដែលមានចំនួន១១៧លើកក្នុងត្រីមាសនេះ គឺតិចជាងត្រីមាសមុនដែលអ្នកតំណាងរាស្ត្រគណបក្សនេះចុះមូលដ្ឋានបាន ១៩២លើក តែចំនួនតំណាងរាស្ត្របានកើនឡើងពី១៤រូប ដល់១៩រូប។

អ្នកតំណាងរាស្ត្រគណបក្ស នរោត្តម រណឫទ្ធិ ចំនួនមានការថយចុះ៦៧% គឺចំនួនពី ៦លើក (មេសា-មិថុនា) ចុះដល់តែចំនួន២លើកក្នុងរយៈ៣ខែនេះ។

ចំណែកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចកើនចំនួន ២៥%ដែលចំនួនការចុះមូលដ្ឋានមាន ២០លើកក្នុងរយៈពេល៣ខែនេះ ប្រៀបធៀបនឹងការចុះមូលដ្ឋាន៣ខែមុនមានចំនួន ១៥លើក ។

ក្នុងចំណោមតំណាងរាស្ត្រទាំង៨១រូបដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាសរុប ៥៥រូប (ស្មើនឹង៦១%នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីសរុប ១៩រូប (ស្មើនឹង៧៣%នៃតំណាងរាស្ត្រគណបក្សនេះសរុប ២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចទាំង២រូប និងតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ ២រូប បានចុះមូលដ្ឋានទាំងអស់ ។

ទោះបីយ៉ាងណា បើគិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗដែលចុះមូលដ្ឋានតាមគណបក្សវិញឃើញថា តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សជាមធ្យមចុះបានច្រើនជាងគេ ដោយក្នុងតំណាងរាស្ត្រមួយរូបចុះមូលដ្ឋានជាមធ្យមចុះបាន ៤៨លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមបាន ៥លើក តំណាងរាស្ត្រសមរង្ស៊ីជាមធ្យមម្នាក់បាន ៧លើក គណបក្សហ៊្វុនស៊ិនប៉ិច ១០លើកក្នុង១រូប និងគណបក្សនរោត្តមរណឫទ្ធិ ១លើក។

***ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស***




បើគិតតាមសមាមាត្រភាគរយនៃតំណាងរាស្ត្រក្នុងរដ្ឋសភាតាមគណបក្ស និងភាគរយនៃ ការចុះមូលដ្ឋានសរុប តាមគណបក្សបង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សដែលមានអាសនៈប្រមាណ៣% បានចុះមូលដ្ឋានបានប្រមាណ២៧% ស្មើនឹង ៩ដងនៃចំនួនអាសនៈសរុប។ ចំណែកអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលមានអាសនៈ២១% នៅរដ្ឋសភាបានចុះមូលដ្ឋានប្រមាណ២៣% ដែលចំនួនចុះមូលដ្ឋានស្មើនឹងជាង ១ដងនៃ ចំនួនអាសនៈដែលគណបក្សនេះមានក្នុងរដ្ឋសភា។ ចំណែក អ្នកតំណាងរាស្ត្រគណបក្សនរោត្តម រណឫទ្ធិ និងហ៊្វុនស៊ិនប៉ិច គឺស្ទើរតែសមាមាត្រទៅនឹងអាសនៈរដ្ឋសភា ដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភា ដែលរួមគ្នាមានអាសនៈ៣%ក្នុងរដ្ឋសភាក៏ចុះមូលដ្ឋានបាន៤%ដែរ។ គណបក្សប្រជាជនកម្ពុជាដែលមានអាសនៈសរុប៧៣%នៅរដ្ឋសភាចុះមូលដ្ឋានបានតែ ៤៦% នៃការចុះមូលដ្ឋានសរុបដែលចំនួននេះ គឺស្មើនឹងជាងពាក់កណ្តាលនៃចំនួនអាសនៈ របស់គណបក្សនេះក្នុងរដ្ឋសភា។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

# សមាជិករដ្ឋសភានៅសល់ ១២២រូប តែការអនុម័តផ្សេងៗនៅតែធៀបនឹងសមាជិកសភា ១២៣

បន្ទាប់ពីអតីតអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ត្រូវបានដកសមាជិកភាពសភាដោយសារប្រធានរដ្ឋសភាមក សមាជិកសភាកម្ពុជាសរុប នៅសល់តែ១២២រូប ដោយគណបក្សសមរង្ស៊ីមិនព្រមបញ្ចូលសមាជិកថ្មីជំនួស ដែលធ្វើឲ្យអាសនៈ ១ដែលជារបស់ គណបក្សសមរង្ស៊ីត្រូវនៅទំនេរ។ ប្រការនេះបានធ្វើឲ្យម្ចាស់ឆ្នោតខ្លះមិនច្បាស់ថា ដោយសារតែសមាជិក រដ្ឋសភានៅសល់តែ ១២២រូប តើការអនុម័តច្បាប់ និងពិភាក្សាធ្វើសេចក្តីសម្រេចលើករណីផ្សេងៗ ត្រូវកំនត់ចំនួនសម្លេង អនុម័តនៃចំនួនសមាជិក សភាសរុប១២២ ឬ១២៣រូប? ក្នុងន័យនេះគឺថា សម្លេងសំរាប់ការអនុម័តដែលត្រូវការ ៥០%+១ តើថា ៥០%+១ នៃ ១២២រូប ឬ ១២៣រូប? បើបញ្ហាមិនបានពិភាក្សាដោះស្រាយឲ្យច្បាស់លាស់ វាអាចបន្តការបកស្រាយ មិនច្បាស់លាស់មួយ ក្នុងករណីអ្នកតំណាងរាស្ត្រតិចជាង១២០នាក់ ដែលមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ បានចែងថារដ្ឋសភា មានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០រូប។

រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៨៨ថ្មី បានកំណត់ចំនួនជាភាគរយច្បាស់លាស់សម្រាប់ដំណើរការប្រជុំ និងការអនុម័តផ្សេងៗ នៃរដ្ឋសភា។ ដូចជាការកំណត់កូរ៉ុមប្រជុំ(ចំនួនអ្នកមានវត្តមានក្នុងពេលប្រជុំសរុប) លើសពីពាក់កណ្តាល និងពេលខ្លះលើសពី ២/៣នៃសមាជិករដ្ឋសភាសរុប។ សម្រាប់ការអនុម័តក៏ដូចគ្នាដែរ ការអនុម័តខ្លះត្រូវការ៥០%+១ ខ្លះទៀត២/៣នៃចំនួន សមាជិកសភាសរុប។

ដូចនេះបញ្ហាថាចំនួនសមាជិកសភាសរុបត្រូវយក១២៣ កំណត់ដោយច្បាប់ស្តីពីការកំនត់ចំនួនអាសនៈរដ្ឋសភា នីតិកាលទី៤ យកចំនួនជាក់ស្តែងដែលសភាកំពុងមាន(១២២រូប) ព្រោះការកំណត់ចំនួនសមាជិកសភាសរុបគឺប៉ះពាល់ដល់ ចំនួនកូរ៉ុម និងសម្លេងសម្រាប់ការអនុម័តផ្សេងៗ ដូចជា បើចំនួនសមាជិកសភាសរុប១២៣រូប ការអនុម័តដែលត្រូវការចំនួន មតិច្រើនដាច់ខាតនៃ៥០ភាគរយបូកមួយ គឺ៦៣សម្លេង។ ប៉ុន្តែប្រសិនបើរដ្ឋសភាយកចំនួនគោល១២២ (ខណៈដែល អ្នកតំណាងរាស្ត្រ សម រង្ស៊ី បាត់បង់សមាជិកភាព) នោះមតិភាគច្រើនដាច់ខាតមាននៃ ៥០%+១ មានចំនួនត្រឹម ៦២សម្លេង។ នេះជាលក្ខខណ្ឌមួយដែលនឹងអាចប្រឈម នៅពេលដែលមតិគាំទ្រ (របៀបវារៈ) ភាគច្រើនដាច់ខាតមានចំនួនត្រឹម ៦២សម្លេង។

ការសង្កេតកន្លងមកបង្ហាញថា រដ្ឋសភានៅតែរក្សាសម្លេងអនុម័ត និងចំនួនកូរ៉ុមធៀបនឹងចំនួន ១២៣រូប ដែលកំណត់ ដោយច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភានីតិកាលទី៤ ដែលមាត្រា១បានចែងថា ចំនួនអាសនៈ រដ្ឋសភានីតិកាលទី៤ ត្រូវកំណត់ត្រឹមមួយរយម្ភៃបី (១២៣)។

អ្នកតំណាងរាស្ត្រ **ជាម យៀប** ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌល ព្រៃវែងរបស់គណបក្សប្រជាជនកម្ពុជាបានពន្យល់នូវនីតិវិធីនេះថា រដ្ឋសភានៅយកកូរ៉ុម ១២៣ ជាគោលនៃមតិច្រើនដាច់ខាត ក្នុងការអនុម័តផ្សេងៗ ព្រោះចំនួននេះត្រូវបានកំណត់ពីដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅកម្ពុជា(គជប)

មិនកែប្រែទេ "*ត្រូវយក១២៣ ព្រោះត្រូវយក ៦៣ ឡើងទៅ សមាជិករដ្ឋសភាមានចំនួនប៉ុននឹង ... ព្រោះកាលបោះឆ្នោត គជប ទទួលស្គាល់ ១២៣រូបហើយ*" ។

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** តំណាងរាស្ត្រមកពីមណ្ឌលភ្នំពេញគណបក្សសមរង្ស៊ី យល់ថារដ្ឋសភា កំនត់យកចំនួនកូរ៉ុមសរុប ១២៣ ដោយសារតែនេះជាចំនួនកំនត់យកតាំងពីដើមអណត្តិដំបូងមក "*ធម្មតាគេយក ១២៣ យើងយកចំនួនដែលគេប្រកាសសុពលភាពតាំងពីដើមអញ្ចឹង*"។

គណបក្សសមរង្ស៊ីប្រកាន់ជំហរមិនដោះដូរសមាសភាពតំណាងរាស្ត្រ ជំនួសអតីតអ្នកតំណាងរាស្ត្រមណ្ឌល កំពង់ចាម លោក **សម រង្ស៊ី** ទេ ព្រោះថាគណបក្សសមរង្ស៊ីមិនទទួលស្គាល់ការកាត់ទោសរបស់តុលាការនេះទេ ដោយយល់ថានេះជារឿងនយោបាយមិនមែនជារឿងព្រហ្មទណ្ឌនោះទេ ហើយលោក សម រង្ស៊ី ក៏នៅតែជាតំណាងរាស្ត្រសំរាប់គណបក្សសមរង្ស៊ី និងសំរាប់ប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យគាត់។ តាមមាត្រា១២០ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានផ្តល់សិទ្ធិដល់គណបក្សនយោបាយ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសសមាជិកសភាណាដែលបាត់បង់សមាជិកភាពសភា។

## តំណាងរាស្ត្រជាស្ត្រីមិនទាន់មានក្រុម និងជួបឧបសគ្គ

ការលើកកំពស់ស្ត្រីចូលរួមក្នុងនយោបាយ បានក្លាយជាសកម្មភាពមួយដ៏សំខាន់របស់ប្រទេសកម្ពុជាដែលរួមមានកំណត់នៅក្នុងគោលដៅសហវត្សការផ្តល់កូតាក្រៅផ្លូវការដោយរាជរដ្ឋាភិបាលសំរាប់តួនាទីរដ្ឋ និងគណបក្សមួយចំនួនមានចលនាស្ត្រីរបស់ខ្លួនទៀត។ តំណាងរាស្ត្រគឺជាតួនាទីដ៏កំពូលមួយនៅក្នុងប្រទេសកម្ពុជា។

ទោះបីយ៉ាងណាអ្នកតំណាងរាស្ត្រស្ត្រីមានតិចតួចចំនួន ២៦រូប (២១% នៃតំណាងរាស្ត្រសរុប ១២៣រូប) បើប្រៀបធៀបនឹងចំនួនប្រជាជនជាស្ត្រីកម្ពុជាសរុបប្រមាណ ៥២%។

នៅខណៈចំនួនតំណាងរាស្ត្រស្ត្រីនៅតិចតួច អ្នកតំណាងរាស្ត្រខ្លះនៅតែជួបឧបសគ្គក្នុងការបំពេញភារកិច្ចត្រូវគេគំរាមមិនឲ្យធ្វើសកម្មភាព មិនត្រូវបានលើកទឹកចិត្តដោយផ្តល់ភាពងាយស្រួល ជាពិសេសមន្ត្រីនៅមូលដ្ឋានដែលបានធ្វើការរើសអើងចំពោះអ្នកនយោបាយមកពីគណបក្សផ្សេងៗ។ ហើយអ្នកតំណាងរាស្ត្រស្ត្រីកម្ពុជានៅតែមិនអាចបង្កើតក្រុមស្ត្រីដើម្បីការពារ និងលើកទឹកចិត្តផលប្រយោជន៍ស្ត្រីដែលពេលនេះសភាមានរយៈពេលជាង១៩ឆ្នាំហើយ ទោះបីជាថ្មីៗនេះ មានការជ្រោមជ្រែង និងលើកទឹកចិត្តពីស្ថាប័នអន្តរជាតិក៏ដោយ។ ដែលប្រទេសក្នុងតំបន់នេះដូចជាប្រទេសវៀតណាមបានបង្កើតឲ្យមានក្រុមស្ត្រីនេះរួមទៅហើយ។

នៅខណៈដែលខ្លួនមានចំនួនតិចហើយមិនអាចចងជាក្រុមបាន នោះតំណាងរាស្ត្រស្ត្រីនឹងពិបាកសម្រេចការងារដើម្បីផលប្រយោជន៍របស់ខ្លួន ជាពិសេសស្ត្រី ហើយការបំពេញតួនាទីរបស់ខ្លួននឹងនៅតែបន្តជួបឧបសគ្គដោយគ្មានការដោះស្រាយដែលអាចបង្កឲ្យជាការបន្ទុចបង្អាក់ដល់តួនាទីស្ត្រីជាគណបក្សប្រឆាំង រារែក ភ័យខ្លាចក្នុងការបំពេញតួនាទីរបស់តំណាងរាស្ត្រ

ស្ត្រីជាអ្នកឃ្លាំមើលសកម្មភាពអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ហើយជាសញ្ញាអវិជ្ជមាន សំរាប់កម្ពុជាក្នុងការលើកកំពស់សិទ្ធិស្ត្រីក្នុងវិស័យនយោបាយ។

នៅក្នុងរដ្ឋសភាកម្ពុជាបច្ចុប្បន្នមានគណបក្សតែ២ប៉ុណ្ណោះ ដែលមានតំណាងរាស្ត្រស្ត្រីតែនិន្នាការនយោបាយនៅតែជាឧបសគ្គដើម្បីបង្កើតក្រុមតំណាងរាស្ត្រស្ត្រីកើតឡើង។ ជាងនេះទៅទៀតអ្នកតំណាងរាស្ត្រស្ត្រីដែលមកពីបក្សផ្សេងគ្នាហាក់មិនជួយគ្នាទៅវិញទៅមកនៅពេលអ្នកតំណាងរាស្ត្រស្ត្រីជួបឧបសគ្គ។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មកពីគណបក្សសមរង្ស៊ីមណ្ឌលកំពត គឺជាអ្នកតំណាងរាស្ត្រសកម្មមួយរូបទាំងការចុះមូលដ្ឋាន និងបញ្ចេញមតិ ទោះបីយ៉ាងណាអ្នកតំណាងរាស្ត្ររូបនេះជារឿយៗត្រូវបានរើសអើងពីពេលខ្លះអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សផ្សេងៗ។ សកម្មភាពអ្នកតំណាងរាស្ត្ររូបនេះពេលខ្លះក៏ត្រូវបានរារាំង និងគំរាមគំហែងពីអាជ្ញាធរមូលដ្ឋានដែរ។

ឧបសគ្គថ្មីៗដែលអ្នកតំណាងរាស្ត្ររូបនេះជួប គឺការប៉ុនប៉ងរារាំងការងារចុះអប់រំប្រជាជនពីការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** នៅសង្កាត់ក្បាលកោះ រាជធានីភ្នំពេញ ពីសំណាក់ មន្ត្រីប៉ូលីស និងចៅសង្កាត់ដោយចោទថា បានធ្វើឃោសនានយោបាយ។

ហើយកន្លងមកថ្មីៗដែរ អ្នកតំណាងរាស្ត្ររូបនេះក៏ត្រូវបានអាជ្ញាធរនៅតាមមូលដ្ឋាន និងជាសមាជិកគណបក្សប្រជាជនបំភិតបំភ័យ ដោយប្រើពាក្យសំដីគំរាមតាមយាយីអ្នករួមដំណើរជាមួយនឹងអ្នកតំណាងរាស្ត្ររូបនេះខណៈដែលអ្នកតំណាងរាស្ត្ររូបនេះបានចុះជួបប្រជាជនក្នុងការអប់រំអ្នកស្រុកពីសិទ្ធិទទួលបានការថែរក្សាសុខភាពនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ នៅក្រុងបាត់ដំបង។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មានប្រសាសន៍ថា វាប៉ះពាល់សិទ្ធិជាតំណាងរាស្ត្រក្នុងការបំពេញតួនាទី និងសុវត្ថិភាព ហើយជារឿងបង្កដោយចេតនានយោបាយ *"វារំលោភដល់សិទ្ធិជាតំណាងរាស្ត្រវាជារឿងគណបក្សប្រជាជនគាត់ថាជាមន្ត្រីមកពីគណបក្សប្រជាជន...ប្រជាជននឹងមិនហ៊ានមកជួបមីង ប៉ះពាល់សិទ្ធិប្រជាជន ប៉ះពាល់ដល់សុវត្ថិភាពរបស់មីង"* ។

ទោះបីយ៉ាងណា ផលវិបាកទាំងនេះហាក់បីដូចជាមិនត្រូវបានទទួលស្គាល់ដោយតំណាងរាស្ត្រស្ត្រីមកពីគណបក្សកាន់អំណាច អ្នកតំណាងរាស្ត្រ **ឃួន សុដារី** ជាតំណារាស្ត្រស្ត្រីមណ្ឌលកណ្តាលមកពីគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា រឿងដែលបានកើតឡើងខាងលើចំពោះអ្នកតំណាងរាស្ត្រ មូរ សុខហួរ នេះជារឿងមិនពិត។

ក្រៅពីកត្តានិន្នាការនយោបាយ អាចមានកត្តានៃការបែងចែកតួនាទីឲ្យមានសមធម៌នៅក្នុងក្រុមតំណាងរាស្ត្រស្ត្រីដែលត្រូវបង្កើត។ មិនមែនមិនមានករណីដែលអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សផ្សេងៗគ្នាចុះមូលដ្ឋានរួមគ្នានោះទេ វាមានក៏ប៉ុន្តែគឺមានតិចតួច។ អ្នកតំណាងរាស្ត្រស្ត្រី **ឃួន សុដារី** បានចាប់អារម្មណ៍ចំពោះការបង្កើតក្រុមស្ត្រីនៅរដ្ឋសភាកម្ពុជា ថាជាការលំបាកក្នុងការបង្កើតឲ្យមានក្រុមស្ត្រីនេះណាស់ ព្រោះទាមទារឲ្យមានឆន្ទៈចូលរួម ពីក្រុមស្ត្រីមកពីគណបក្សប្រឆាំងផងដែរ *"ចង់ចងក្រងក្រុមស្ត្រីដែរ តែអត់មានស្ត្រីគណបក្សប្រឆាំងចូលរួម ពិបាកហៅចូលណាស់...ហើយក៏មិនអាចអត្តនោម័តទេ [ដើម្បីបង្កើតក្រុមស្ត្រីរបស់រដ្ឋសភានេះ] ព្រោះត្រូវការប្រជុំអនុម័តពិភាក្សា"*។

ជាមួយនេះដែរ អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មកពីគណបក្សសមរង្ស៊ីធ្លាប់បានលើកឡើងថា *"គ្មានតម្លាភាព [ក្នុងការបែងចែកតួនាទីក្នុងក្រុមស្ត្រីរបស់រដ្ឋសភា]។ [ឧទាហរណ៍] ខ្ញុំធ្លាប់បានចូលរួមជាមួយក្រុមស្ត្រីគណៈកម្មការតាមខេត្តមួយចំនួនទៅចែកអំណោយ។ ធ្វើសន្ទរកថា ឱ្យប្រធានក្រុមមានសិទ្ធិនិយាយ។ ប្រធានមកពីគណបក្សកាន់អំណាចទៀត ហើយយើងទៅបានអង្គុយល្មមើល ការចាត់ចែងមិនស្មើភាព។"*

ទាំងអ្នកតំណាងរាស្ត្រស្ត្រីកាន់អំណាច និងប្រឆាំងសុទ្ធតែចង់បង្កើតក្រុមស្ត្រី ក៏ប៉ុន្តែសុទ្ធតែមើលឃើញថានិន្នាការខុសគ្នាគឺជាឧបសគ្គដ៏ធំ។ ដូចនេះការចង់បង្កើតក្រុមតំណាងរាស្ត្រស្ត្រីបាន គឺវាពឹងផ្អែកទៅលើឆន្ទៈរបស់តំណាងរាស្ត្រស្ត្រីផ្ទាល់ ដែលយកបញ្ហាស្ត្រីដាក់លើនិន្នាការនយោបាយរបស់គណបក្សដែលគ្រប់គ្រងដោយបុរសៗ។ ជាមួយគ្នាដែរ ច្បាប់បោះឆ្នោតដែលកំណត់សមាជិកភាពតំណាងរាស្ត្រត្រូវបាត់បង់នៅពេលបាត់បង់សមាជិកភាពពីគណបក្ស គួរលុបបដើម្បីផ្តល់អំណាចតំណាងរាស្ត្រ ក្នុងការតស៊ូមតិជាមួយនគណបក្ស។

## សង្ខេបព្រឹត្តិការណ៍ប្រជុំសភាអាស៊ាន (AIPA)ដែលរដ្ឋសភាកម្ពុជាជាម្ចាស់ផ្ទះ

## ថ្ងៃទី១៨ ដល់ ២៤ ខែកញ្ញា ឆ្នាំ២០១១

កិច្ចប្រជុំសភាអាស៊ានដែលធ្វើឡើងក្នុងប្រធានបទ "តួនាទីអាយប៉ាក្នុងការកសាងសហគមន៍អាស៊ានមួយប្រកបដោយវិបុលភាព" បានធ្វើឡើងក្នុងរយៈ៧ថ្ងៃ នៅវិមានសន្តិភាពនៃគណៈរដ្ឋមន្ត្រី។ ការប្រជុំនេះ ដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងតំបន់រួមគ្នារបស់ប្រទេសជាសមាជិកអាស៊ាន និងគោលដៅដើម្បីបង្កើត សហគមន៍អាស៊ានដើម្បីរកឲ្យបាននូវដំណោះស្រាយដែលមានស្ថេរភាពមួយ។ សន្និបាទនេះមានការចូលរួមពីសមាជិកសភាមកពីប្រទេសជាសមាជិកអាស៊ាន និងប្រទេសអង្កេតផ្សេងៗទៀត ដូចជាជប៉ុន សភាអឺរុប ប្រទេសអូស្ត្រាលី កាណាដា ចិន ឥណ្ឌា និងរុស្ស៊ី ហើយក្នុងនោះដែរកម្ពុជាជាប្រធានអាយប៉ាលើកទី៣២។ ក្នុងនោះសង្កេតឃើញដែរថា មានតំណាងរាស្ត្រមកតែ ៣គណបក្ស ប៉ុណ្ណោះដែលបានចូលរួមក្នុងការប្រជុំ សភាអាស៊ាន គឺគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សជាសមាជិក និងប្រធានគណៈកម្មការនៃកិច្ចប្រជុំអាយប៉ា។

លទ្ធផលនៃការប្រជុំសភាអាយប៉ាលើកទី៣២នេះ គឺបានសំរេចលើការព្រាងលើដំណោះស្រាយប្រកបដោយចេរភាពនូវបញ្ហាប្រឈមថ្មី និងបានឯកភាពលើរបាយការណ៍មួយចំនួនដែលបំពេញរយៈពេលមួយឆ្នាំ ដែលកម្ពុជាជាប្រធានអាយប៉ា និងបានអនុម័តសេចក្តីសំរេចចំនួន២៥ចំនុច ដែលមានដូចជា សន្តិសុខ នយោបាយ សេចដ្ឋកិច្ច សង្គម និងវប្បធម៌ បញ្ហាប្រជាជន និងការអភិវឌ្ឍន៍ដោយចេរភាព បញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងគ្រោះមហន្តរាយ ជំងឺឆ្លងនានា គ្រោះថ្នាក់ដោយសារគ្រាប់មីន និងផ្លាស់ប្តូរបទពិសោធន៍ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសង្កេតការណ៍ និងសេចក្តីថ្លែងការណ៍រួម។

តាមសំដីអ្នកតំណាងរាស្ត្រ **ឈាង វុន** ជាប្រធាននៃកិច្ចពិភាក្សាគណៈកម្មការបានមានប្រសាសន៍ថា កិច្ចពិភាក្សានេះនឹងជំរុញធ្វើឲ្យកម្ពុជាកសាងសមត្ថភាពដើម្បីធ្វើសមាហរណកម្មសេចក្តីចូលអាស៊ាន និងពិភាក្សាពីការត្រៀមខ្លួនរបស់អាស៊ាន

សំរាប់សំរបនឹងបំរែបំរួលបរិស្ថាន *"ដើម្បីឲ្យអាស៊ានថ្មី គឺវៀតណាម ឡាវ កម្ពុជា អាចធ្វើសមាហរណកម្មសេចក្តីខ្លួនទៅក្នុងអាស៊ាន បានដើម្បីត្រៀមខ្លួនរៀបចំរួមចំណែក កសាងសហគមន៍អាស៊ាននៅឆ្នាំ២០១៥។ ចំនុចមួយទៀត ឲ្យយល់ថាបរិស្ថានវាខូចខាតទាំងមូល ពិសេសមូលហេតុមកពីប្រទេសឧស្សាហកម្មធំៗ កុំឲ្យមានការចោទគ្នាមកពី ប្រទេសតូចកាប់ព្រៃឈើ ឬប្រទេសធំៗ បញ្ចេញឧស្ម័ន ហើយបញ្ហានេះជាបញ្ហាធំ យើងទទួលស្គាល់បញ្ហា យើងត្រូវយកចិត្តទុកដាក់ថាតើបរិស្ថានខូចហើយនេះ តើយើងត្រូវបន្សុំខ្លួនយើងដែលជាពលរដ្ឋរបស់ អាស៊ានត្រូវធ្វើយ៉ាងមេច។"*

ថវិកាសំរាប់ចំណាយលើការចំណាយទូទៅលើការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាយប៉ានេះ ចំនួន១,៣ លានដុល្លារអាមេរិច ផ្តល់ដោយរាជរដ្ឋាភិបាល ដែលគម្រោងស្នើរបស់រដ្ឋសភាមានចំនួន ១,៩ លានដុល្លារ។ ដែលកន្លងមកមានការរិះគន់ពីតំណាងរាស្ត្រមកពីគណបក្សប្រឆាំងថា ការចំណាយនេះមាន លក្ខណៈខ្ជះខ្ជាយ និងសកម្មភាពជំរុញឲ្យមានដោះស្រាយបញ្ហាមួយចំនួន អាយប៉ានៅមិនទាន់បានបំពេញតួនាទីឲ្យមានប្រសិទ្ធិភាពនៅឡើយទេ និងថាការរៀបចំនេះគឺគ្រាន់តែដើម្បីលើកំពស់មុខមាត់គណបក្សកាន់អំណាចប៉ុណ្ណោះ។ អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានមានប្រសាន៍ថា *"កិច្ចប្រជុំ AIPAនេះ តាមកម្មវិធីរៀបចំ គឺគ្រាន់តែជាការរៀបចំដើម្បីឲ្យអ្នកមកចូលរួមទទួលបានការធ្វើដំណើរកម្សាន្ត គឺអស់ទឹកប្រាក់ច្រើនណាស់។"*

សភាអាយប៉ា (AIPA) ដែលមានប្រទេសចំនួន ១០ នោះបានវិវត្តន៍ពីឈ្មោះសម្ព័ន្ធភាពរបស់សមាគមន៍អន្តរសភា (AIPO) បានបង្កើតឡើងតាំងពីឆ្នាំ១៩៧០ ដែលមានប្រទេសសមាជិកអាស៊ានចំនួន ៥ ដូចជា ប្រទេសឥណ្ឌូនេស៊ី ភីលីពីន ម៉ាឡេស៊ី សិង្ហបុរី ថៃ ជាស្ថាបនិក ដែលក្នុងនោះសភាប្រទេសឥណ្ឌូនេស៊ី ជាប្រទេសផ្តួចផ្តើមគំនិត។ ហើយកម្ពុជាចូលជាសមាជិកអន្តរសភា (អាយប៉ា) តាំងពី ១៩៩៩។ គោលបំណងនៃអន្តរសភាអាស៊ាននេះ គឺដើម្បីប្រតិបត្តិការលើការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងតំបន់តាមរយៈកម្មវិធីនៃការសហប្រតិបត្តិការផ្សេងៗដើម្បីការពារស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់ប្រឆាំងនឹងការប្រកួតប្រជែងពីមហាអំណាច ហើយក៏ជាវេទិកាមួយដើម្បីធ្វើសេចក្តីសំរេចចិត្តចំពោះបញ្ហាផ្សេងៗក្នុងតំបន់។ រាល់ការប្រជុំរបស់អន្តរសភាអាស៊ានហៅកាត់ថាអាយប៉ានេះ គឺតែងតែមានការចូលរួមពីខាងគណៈប្រតិភូអង្កេតការណ៍ជាប្រទេសជាដៃគូផងដែរ។

❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄

ទិន្នន័យការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានប្រមូលមកពី៖ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនីមួយៗ សាខាគណបក្សជាប់ឆ្នោតនីមួយៗនៅតាមខេត្ត គេហទំព័រ (website) របស់គណបក្ស ប្រព័ន្ធផ្សព្វផ្សាយ និង របាយការណ៍របស់អ្នកតំណាងរាស្ត្រ។

អ្នកតំណាងរាស្ត្រអាចផ្តល់ព័ត៌មានពីការចុះមូលដ្ឋានរបស់ខ្លួនតាមអស័យដ្ឋានដូចខាងក្រោម៖

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥
ទូរស័ព្ទ ០២៣ ៨៨៤ ១៥០/០១២ ៩៤២ ០១៩ ទូរសារ ០២៣ ៨៨៥ ៧៤៥
អ៊ីម៉េល៖ comfrel@online.com.kh គេហទំព័រ៖

ខុមហ្វ្រែល COMFREL